# ឆាយាធម៌

ឆាយាធម៌= ធម៌ជាម្លប់

**នមោតស្ស**

**ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

សូមនមស្សការថ្វាយបង្គំ ចំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះសង្ឃ) ដោយសេចក្តីគោរព។

**ឥតោ បរំ ឆាយាធម្មំ ទេសេស្សាមិ**

ដទៃអំពីបទនមស្សការនេះទៅ អាត្មាភាព សូមលើកយកឆាយាធម៌មកសំដែង ចែកជូនដល់ពុទ្ធបរិស័ទទាំងឡាយ ដើម្បីជាទីសណ្តាប់ ជាគ្រឿងប្រដាប់សតិ បញ្ញាស្មារតី ដូចសេចក្តីតទៅនេះ៖

ឆាយាធម៌មាន៦ យ៉ាងគឺ៖

**១.-មាតាបិតុឆាយា=ម្លប់គឺមាតាបិតា**

**២.-គរុឆាយា=ម្លប់ គឺគ្រូ**

**៣.-ញាតិឆាយា=ម្លប់គឺញាតិ**

**៤.-រាជឆាយា=ម្លប់គឺព្រះរាជា**

**៥.-សាសនាឆាយា=ម្លប់គឺសាសនា**

**៦.-រុក្ខឆាយា=ម្លប់គឺដើមឈើ**

សូមលើកយកមកអធិប្បាយម្តងមួយៗ តាមលំដាប់មាតិកា ដូចតទៅ៖

# អធិប្បាយ

## មាតាបិតុឆាយាទី១

ឆាយា ស័ព្ទនេះប្រែថា << ម្លប់ឬស្រមោល>> ។ ក្នុងទីនេះគួរប្រែថា << ម្លប់>> ទើបត្រូវល្អជាង ពាក្យថា<< ឆាយាធម៌ >> ប្រែថា<< ធម៌ជាម្លប់ >> ។

ពាក្យថា << មាតា>> បានសេចក្តីថា ស្រីឯណាដែលអាចញ៉ាំងបុត្រឱ្យកើតឡើងបាន ហៅថាមាតាគឺម្តាយ ។

ពាក្យថា << បិតុ>> បានសេចក្តីថា ប្រុសឯណាដែលអាចញ៉ាំងបុត្រឱ្យកើតឡើងបាន ហៅថាបិតុឬបិតាគឺឪពុក ។ សម និងបទបាលីថា៖

**មាតា នាម ជនិតា បិតា នាម**

**ជនកោ តេសុ មាតាវ ឧក្ករការិកា ។**

ប្រែថា ស្ត្រីឯណាដែលជាអ្នកអាចញ៉ាំងកូនឱ្យកើតឡើងបាន ស្ត្រីនោះបាននាមបញ្ញត្តិថាមាតាគឺម្តាយ ។

បុរសឯណាដែលជាអ្នកអាចញ៉ាំងកូនឱ្យកើតឡើងបាន បុរសនោះបាននាមបញ្ញត្តិថាបិតាគឺឪពុក ។

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា៖

**ឧភោបិ ចេតេ ព្រហ្មា បុព្វទេវា**

**បុព្វចរិយោ អាហុនេយ្យាតិ វុច្ចតិ**

ប្រែថាអ្នកដ៏មានគុណទាំពីរ នោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់សំដែងឱ្យឈ្មោះជា ៤ យ៉ាងគឺ៖

**១**.-**ព្រហ្ម** អ្នកមានព្រហ្មវិហារធម៌

**២**.-**បុព្វទេវា** ទេវតាខាងដើម

**៣**.-**បុព្វចរិយា** ជាអាចារ្យខាងដើម

**៤**.-**អាហុនេយ្យ** ជាអ្នកដែលបុត្រគប្បីគោរពបូជា ។

សេចក្តីបញ្ជាក់

ពាក្យថា មាតា មកអំពីស័ព្ទដើមគឺមានធាតុនិងរាគុបច្ច័យ បទវិគ្គហៈថា បុត្តំ មានេតីតិ ជា មាតា(ឥត្ថី) ស្រីឯណា តែងរាប់អាន នូវកូន ស្រីនោះឈ្មោះថា មាតា ។

ពាក្យថា បិតា មកអំពីស័ព្ទដើមគឺបាល+រិតុ បទវិគ្គហៈថា បុត្តំបាលេតីតិ > បិតា(បុរិសោ) បុរសឯណា តែងរក្សានូវកូន បុរសនោះមានឈ្មោះថាបិតា ។

ពាក្យថា បុត្ត មកអំពីស័ព្ទដើមគឺបុ+ត បទវិគ្គហៈថា បិតុទុក្ខំ បុនាតីតិ > បុត្តោ(ជនោ) ជនឯណាតែងជម្រះ នូវទុក្ខរបស់បិតា ជននោះមានឈ្មោះថាកូន ។

បទវិគ្គហៈ មួយបែបទៀតថា អត្តនោ កុលំ បុនាតិ សោធេតីតិ > បុត្តោ(ជនោ) ជនឯណាជំរះគឺថាបំពេញនូវត្រកូលរបស់ខ្លួន ជននោះឈ្មោះថាកូន ។

មែនពិត! មាតាបិតា ជាអ្នកមានគុណូបការចំពោះបុត្រធីតា ចំណែកអ្នកប្រាជ្ញប្រសើរទាំងឡាយ តួយ៉ាងដូច ជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលពលលោករាប់ច្រើនរយ ច្រើនលានគោរពបូជា រមែងសម្តែងថា មាតាបិតាជាអ្នកមានគុណអនន្តធ្ងន់អនេកអន័ត្ប ចំពោះបុត្រធីតាគ្រប់ៗគ្នាត្រូវរលឹកដឹងគុណនិងតបស្នងសងលោកវិញតាមសមគួរ ។

សេចក្តីនេះសមនឹងព្រះពុទ្ធដីកាដែលមានមកក្នុងគម្ពីរ ខុទ្ទកនិកាយជាតក សត្តតិនិបាតថា៖

## ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ
## អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា ១

លោកហៅមាតាបិតាថា ព្រហ្ម ថាបុពាចារ្យ ថាអាហុនេយ្យៈ របស់បុត្រទាំងឡាយផង ថាជាអ្នកអនុគ្រោះដល់ពួកសត្វផង ។

មាតាបិតា ជាអ្នកមានគុណចំពោះបុត្រទាំងឡាយ ព្រោះលោកជាអ្នកឱ្យកំណើត ចំពោះបុត្រធីតាផង ជាអ្នកចិញ្ចឹមបីបាច់ថែរក្សាទំនុកបំរុងផង ក្នុងហេតុផលនេះហើយ ដែលអ្នកប្រាជ្ញទាំងឡាយ បានពន្យល់ថាមាតាបិតា មានគុណធំជាងភ្នំព្រះសុមេរ៍ ទូលាយជាងមហាសមុទ្រ ធ្ងន់លើសផែនដី ព្រោះមិនអាចសរសេរសរសើរគុណ ចិត្តល្អរបស់លោក ឱ្យចប់សព្វគ្រប់អស់ឡើយ ហេតុនេះហើយ ទើបព្រះពុទ្ធដីកា លើកតម្កើងមាតាបិតាទុកជាព្រហ្ម ជាបុព្វាចារ្យ ជាអាហុនេយ្យៈ ។

មាតាបិតាដែលមានឈ្មោះថាព្រហ្ម ព្រោះជាអ្នកប្រសើរខ្ពង់ខ្ពស់ ដោយព្រហ្មវិហារធម៌៤យ៉ាងចំពោះបុត្រធីតាគឺ មេត្តា ករុណា មុទិតា ឧបេក្ខា តាំងពីកូននៅក្នុងផ្ទៃ រហូតប្រសូតមកលោកមានសេចក្តីស្រឡាញ់រាប់អាន ចង់ឱ្យរួចចាកទុក្ខវិបត្តិ ឱ្យមានសេចក្តីសុខចម្រើន កើនដោយសុខភាពនៃរាងកាយ ចំរើនដោយចំណេះវិជ្ជា គុណធម៌ ទ្រព្យសម្បត្តិ យសសក្តិជាដើមកាល

បើកូនបានសុខចំរើន កើនប្រយោជន៍ឧត្តុងឧត្តមយ៉ាងណា ក៏មានតែសេចក្តីត្រេកអរតាម គ្មានច្រណែនបែនទារ សូម្បីតិចតួចឡើយ ហើយរមែងរាយមេត្តា ករុណា មុទិតា ផ្សព្វផ្សាយ ស្មោះសរទៅកូនគ្រប់គ្នា ។ ដោយមាតាបិតា ឋិតនៅក្នុងព្រហ្មវិហារធម៌ចំពោះបុត្រធីតាទាំងឡាយដូច្នេះហើយ ទើបនាំឱ្យលោកខិតខំបីបាច់ចិញ្ចឹមថែរក្សា ស៊ូទ្រាំនឹងសេចក្តីនឿយលំបាកគ្រប់យ៉ាង ដើម្បីសាងជីវិតកូនឱ្យរស់នៅឱ្យមានសេចក្តីសុខ រួចចាកភ័យវិបត្តិទាំងពួង តាមសមត្ថភាពដែលលោកអាចធ្វើបានត្រឹមណា ។ អាស្រ័យព្រហ្មវិហារធម៌ ដក់ជិតឋិតនៅក្នុងចិត្តមាតាបិតាយ៉ាងនេះហើយ ទើបអ្នកប្រាជ្ញហៅថាមាតាបិតាជាព្រហ្មរបស់បុត្រធីតាទាំងឡាយ ។

មាតាបិតា មានឈ្មោះថា បុព្វាចារ្យ គឺគ្រូអាចារ្យមុនដំបូងបង្អស់ មុនគ្រូអាចារ្យដទៃៗ របស់បុត្រធីតា ដោយន័យថាមាតាបិតាជាអ្នកបង្ហាត់បង្រៀននូវបឋមវិជ្ជា មូលដ្ឋាននៃមនុស្សលោកគឺដេកដើរ ឈរអង្គុយ និយាយស្តី ហៅរក ស្គាល់ម៉ែឪ យាយតា មាមីង និងកិរិយាវាចាត្រូវប្រព្រឹត្តយ៉ាងណាចំពោះជនទាំងនេះ វិជ្ជាមូលដ្ឋាននៃមនុស្សលោកនេះហើយ ដែលមាតាបិតាបង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់ ដោយសប្បាយរីករាយ គ្មានចេះនឿយហត់ហើយគ្មានគិតរង្វាន់ខាន់ខៅអ្វីឡើយ បើគ្មានវិជ្ជាមូលដ្ឋាននៃមនុស្សលោកនេះ ជាខាងដើមទេ គ្រូទាំងឡាយដទៃដែលបង្រៀនវិជ្ជាផ្សេងៗទៀត មានអក្សរ លេខ នព្វន្ត គុណហាជាដើម ក៏មិនងាយនឹងបង្ហាត់បង្រៀនបានឡើយ ដូច្នេះមាតាបិតាឈ្មោះថាបុព្វាចារ្យ គ្រូអាចារ្យខាងដើមរបស់បុត្រធីតាដោយន័យដូចបានសម្តែងមកហើយ ឯគ្រូអាចារ្យក្រៅពីនេះគឺបច្ឆាចារ្យ គ្រូអាចារ្យខាងក្រោយ បន្តបេសកកម្មពីមាតាបិតាមក ។

មាតាបិតា មានឈ្មោះថាអាហុនេយ្យៈ ព្រោះជាអ្នកគួរទទួលនូវការគោរពបូជាអំពីកូនទាំងឡាយដោយន័យថា មាតាបិតាជាអ្នកមានចិត្តស្អាតបរិសុទ្ធ ចំពោះកូន ថែមទាំងជាអ្នកប្រកបដោយព្រហ្មវិហារធម៌ និងជាបុព្វាចារ្យចំពោះកូន ដូចបានពន្យល់មកហើយ ដូច្នេះមាតាបិតា សមគួរនឹងបានទទួលទំនុកបំរុង ការគោរពបូជា ការថែរក្សា ការពារថ្នាក់ថ្នម ពីកូនប្រុស-ស្រីទាំងឡាយវិញ ដូចព្រះអរិយបុគ្គល សមនឹងទទួលការគោរពបូជា ពីសត្វលោកយ៉ាងណា មាតាបិតាក៏សមជាបុគ្គលទទួលសក្ការបូជា ពីបុត្រធីតាទាំងឡាយ យ៉ាងនោះដែរ ។ នេះជាន័យថា មាតាបិតាជាអាហុនេយ្យៈរបស់បុត្រធីតាទាំងឡាយ ។

មាតាបិតា ឈ្មោះថាព្រហ្ម បុព្វាចារ្យ អាហុនេយ្យៈ របស់បុត្រធីតាទាំងឡាយ ទាំងឈ្មោះថាជាអ្នកអនុគ្រោះដល់ពួកសត្វផង ព្រោះថា បើកុំតែមាតាបិតាមានគុណធម៌ ដូចសម្តែងមកហើយ ធ្វើម្តេចឡើយ កូនចៅនឹងរស់រានបាន ម្យ៉ាងទៀតតម្រាយនៃការប្រព្រឹត្តិនោះ បានក្លាយជាទំនៀមទម្លាប់ល្អ តមកជាប្រយោជន៍ ដល់មនុស្សដែលកើតមកតៗមកទៀតទើបឈ្មោះថា ជាអ្នកអនុគ្រោះដល់ពួកសត្វផង ។

តាមពិត! មាតាបិតា ដែលឱ្យកំណើតនិងចិញ្ចឹមនូវកូន ប្រុស-ស្រីឱ្យរស់រានមានជីវិតត្រឹមតែប៉ុណ្ណោះ ក៏មានឈ្មោះថាជាគុណធំណាស់ទៅហើយ តែមាតាបិតា ដែលឈ្លាសវៃ រមែងអនុគ្រោះចំពោះកូនដោយលក្ខណៈ៥ យ៉ាងគឺ៖

**១.-បាបា និវារេន្តិ** រមែងតាមហាមឃាត់ មិនឱ្យធ្វើអំពើអាក្រក់ផ្សេងៗ ។

**២.-កល្យាណេ និវាសេន្តិ** រមែងញ៉ាំងបុត្រធីតា ឱ្យតាំងនៅក្នុងអំពើល្អ គឺអំពើណាដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីល្អប្រពៃ ដែលនឹងនាំមកនូវសេចក្តីសុខចម្រើន និងប្រយោជន៍ដល់កូន និងវង្សត្រកូលរមែងដឹកនាំ ប្រៀនប្រដៅបុត្រធីតាក្នុងអំពើប្រពៃ ដែលជាផ្លូវនាំឱ្យបុត្រធីតា បានទៅជាអ្នកមានអធ្យាស្រ័យ សុចរិត យុត្តិធម៌ ។

**៣.-សិប្បំ សិក្ខាបេន្តិ** ឱ្យបុត្រធីតា បានសិក្សាសិល្បវិជ្ជា មានអក្សរនិងលេខនព្វន្តជាដើម ឱ្យបានទៅជា អ្នកឈ្លាសវៃក្នុងវិទ្យាសាស្ត្រ សង្គមសាស្ត្រ មនុស្សសាស្ត្រ និងវប្បធម៌ជាដើម។

**៤.-បដិរូបេន ទារេន សំយោជេន្តិ** ផ្សំផ្គុំបុត្រធីតាឱ្យជាស្វាមីភរិយា តាមសមគួរដល់វ័យនិងវង្សត្រកូល ។

**៥.-សមយេ ទាយជ្ជំ និយ្យាទេន្តិ** ប្រគល់ទ្រព្យមត៌កឱ្យក្នុងសម័យដ៏គួរ គឺកាលបុត្រធីតាមានគូស្វាមីភរិយាហើយ គួរបែងចែកកេរ្តិ៍ មត៌កឱ្យសម្រាប់ ជំនួយផ្តល់ទុនក្នុងការស្វែងរកផលប្រយោជន៍ ចិញ្ចឹមជីវិត តទៅ។

កូនប្រុស-ស្រីទាំងឡាយ! កាលបើពិចារណាឃើញថា មាតាបិតា ជាអ្នកមានឧបការគុណយ៉ាងលើសលប់ពន់ប្រមាណ ដូចបានសម្តែងមកហើយ គប្បីធ្វើខ្លួនជាកូនកតញ្ញូកតវេទីចំពោះលោកវិញ ។

ដោយគុណធម៌ របស់មាតាបិតា មានមកលើបុត្រធីតាដូចបានពោលមកហើយ ទើបព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា មាតាបិតុជា **ម្លប់គឺមាតាបិតា** ។

# គរុធាយាទី២.-

ពាក្យថា <<**គរុ**>> ប្រែថាយូរឬធ្ងន់ បើប្រើជាបទនាមប្រែថា គ្រូ គ្រូបាអាចារ្យ លោកជាអ្នកមានគុណូបការច្រើនចំពោះសិស្សានុសិស្ស ព្រោះលោកជួយបង្ហាត់បង្រៀនប្រៀនប្រដៅ ហ្វឹកហ្វឺន នូវមុខវិជ្ជាសព្វយ៉ាង ទាំងវិជ្ជាផ្លូវលោក ទាំងវិជ្ជាផ្លូវធម៌ ដោយមិនគិតពីការនឿយហត់ អ្វីឡើយ ។

ពាក្យថា << **អាចារ្យ** >> មានអត្ថន័យថា អ្នកមានខ្លួនទូន្មានល្អហើយ អ្នកហាត់ពត់ អ្នកមានសណ្តាប់ធ្នាប់ល្អ ចរិយាមារយាទបូកពាថ្លៃថ្នូរ អ្នកប្រព្រឹត្តល្អ អ្នកកាន់ធម៌ត្រឹមត្រូវ អ្នកប្រដៅបង្ហាត់បង្ហាញដល់អ្នកដទៃ អ្នកដែលសិស្សគប្បីគោរពបូជា អ្នកធ្វើប្រយោជន៍ដល់សិស្សទូទៅ ។

ពាក្យថា គ្រូ និងពាក្យថាអាចារ្យ ទាំងពីរម៉ាត់នេះជាវេវចនៈហៅផ្លាស់ប្តូរគ្នា ខ្មែរយើង ចូនកាលហៅគួបគ្នាថាគ្រូបាអាចារ្យ ឬគ្រូបាធ្យាយ ។

គ្រូអាចារ្យត្រូវប្រកបដោយអង្គ៥ គឺ៖

១.-**ហិរិ** សេចក្តីខ្មាសបាប

២.-**ឱត្តប្បៈ** សេចក្តីក្រែងបាប

៣.-**អនុទយៈ** សេចក្តីអាណិតអាសូរ

៤.-**សតិ** សេចក្តីរលឹកបាន

៥.-**ខន្តី** សេចក្តីអត់ធន់ ។

គ្រូអាចារ្យមានគុណសម្បត្តិ៧ យ៉ាងទៀតគឺ៖

១.-**បិយោ** ជាទីស្រឡាញ់ពេញចិត្តនៃសិស្ស

២.-**គរុ** ជាទីគោរពនៃសិស្ស

៣.-**ភាវនីយោ** ជាទីសរសើរនៃសិស្ស

៤.-**វត្តា** ឧស្សាហ៍និយាយប្រៀនប្រដៅ

៥.-**វចនក្ខមោ** អត់ធន់នឹងពាក្យសម្តី

៦.-**គម្ភីរំ កថំ កត្តា** ពោលពាក្យដ៏ជ្រាលជ្រៅ

៧.-**នោ អដ្ឋានេ** និយោជេន្តិ មិនដឹកនាំសិស្សឱ្យស្ថិតនៅក្នុងផ្លូវឥតប្រយោជន៍។

គ្រូអាចារ្យ ត្រូវអនុគ្រោះសិស្ស ដោយស្ថាន៥ យ៉ាងគឺ៖

១.-**សុវិនីតំ វិនេន្តិ** ទូន្មាន ប្រៀនប្រដៅសិស្សដោយល្អ ។

២.-**សុគ្គហិតំ គាហាបេន្តិ** បង្ហាត់បង្រៀនសិស្សដោយល្អ។

៣.-**សព្វសិប្បេសុ តំ សមក្ខាយិនោ ភវន្តិ** បង្ហាត់បង្រៀនសិស្ស គ្រប់សិល្បសាស្ត្រ ចំណេះវិជ្ជាដែលខ្លួនចេះ ។

៤.-**មិត្តមច្ចេសុ បដិវេទន្តិ** សម្តែងគុណសម្បត្តិសសិស្សក្នុងកណ្តាលជំនុំមិត្រ និងអាមាត្យ ។

៥.-**ទិសាសុ បរិត្តានំ ករោន្តិ** ធ្វើនូវសេចក្តីការពាររក្សាសិស្សសព្វទិស។

គ្រូអាចារ្យ លោកប្រកបដោយគុណធម៌យ៉ាងនេះ ហើយទើបលោកបានទាម **គរុឆាយា ម្លប់គឺគ្រូ**។

# ញាតិឆាយាទី៣.-

ពាក្យថា <<**ញាតិ**>> ប្រែថាជនដែលគេគប្បីដឹង ឬប្រែថា ជនដែលគេគប្បីរលឹក។ អ្នកដែលរួមខ្សែលោហិត ទាំងខាងមាតា ទាំងខាងបិតា ដែលនិយមហៅថា ញាតិ៧សន្តាន ឬញាតិ៧ជួរ ។

តាមន័យក្នុងគម្ពីរពុទ្ធសាសនា លោកឱ្យរាប់ខាងលើ៣ជួរ ស្រករខ្លួន១ជួរ ខាងក្រោមខ្លួន៣ជួរ ត្រូវជា៧ជួរ។

ខាងលើខ្លួន៣ជួរគឺ៖

ស្រករមាតាបិតាខ្លួន១ជួរ ស្រករជីដូន ជីតាខ្លួន១ជួរ ស្រករជីដូនទួត ជីតាទួត១ជួរ។

ស្រករខ្លួនគឺ៖

ពួកបងប្អូនបង្កើត ជីដូនមួយ ជីទួតមួយ ១ជួរ។

ខាងក្រោមខ្លួន៣ជួរគឺ៖

ស្រករនឹងកូនខ្លួន (ពួកក្មួយ) ១ជួរ ស្រករនឹងចៅខ្លួន(ពួកចៅ)១ជួរ ស្រករនឹងចៅទួតខ្លួន(ពួកចៅទួត)១ជួររួមត្រូវជា៧ជួរ។

ទក្ខិណាវិភង្គ សំដែងអំពីពាក្យថាញាតិ

ញាតិមានពីរយ៉ាងគឺ៖

១.-ញាតិកា រាប់យក៣លើ ៣ក្រោម។

២.-ញាតិធម៌ ឬញាតិបេតា ឪពុកម្តាយ រហូតដល់តាទួត ជីទួត(រាប់៣លើ ៣ក្រោម) ។

ញាតិ៧សន្តានមាន២ យ៉ាង គឺ៖

១.-ញាតិ ខ្សែផ្ទាល់

២.-ញាតិ សាខា

ក) ញាតិខ្សែផ្ទាល់ ខ្លួនយើងរហូតដល់ទៅក្រោម ចំប៉ាចុងគល់។

ខ) ញាតិសាខា រាប់ខាងបងរហូត ឬប្អូនរហូត។

បុត្រធីតាទាំងឡាយកាលបើអត់ពីមាតាបិតាជាទីពំនឹងហើយ ក៏តោងអាស្រ័យទៅលើ ពួកញាតិជាអ្នកជួយឃុំគ្រងបីបាច់ថែរក្សា ជាអាណាព្យាបាល បើមិនមានញាតិ ជាពំនឹងនិងពំនាក់ទេ ក៏ការរស់នៅមិនបានប្រព្រឹត្តទៅបានដោយស្រួលឡើយ។

ម្យ៉ាងទៀត ការសង្គ្រោះដល់ពួកញាតិ ក៏រាប់ថាជាពលី ដូចបទបាលីថា ញាតិសង្គហោការសង្គ្រោះដល់ពួកញាតិ ចាត់ទុកជាមង្គល ដ៏ឧត្តម។

ការជួយដោះទុក ក្រុមញាតិ ដែលកំពុងសាបសូន្យហិនហោចចាកទ្រព្យសម្បត្តិ ដោយការផ្តល់ទ្រព្យសម្បត្តិឱ្យក្រុមញាតិ ដែលកំពុងតែឈឺចាប់រ៉ាំរ៉ៃ ដោយការជួយអភិបាលរក្សារោគាព្យាធិនោះ ជាដើម ឈ្មោះថា ការសង្គ្រោះញាតិ ។ ការសង្គ្រោះញាតិនោះ ព្រះបរមគ្រូជាម្ចាស់ត្រាស់ថាជាមង្គល ព្រោះជាហេតុបាននូវគុណវិសេស ក្នុងជាតិខាងមុខផង ជួនកាលបានទៅកាន់ស្ថានសួគ៌ទាំងបច្ចុប្បន្នជាតិនេះផង ក៏មាន។ ហេតុនេះ ការសង្គ្រោះញាតិនោះ ជាកិច្ចគឺបុគ្គលគ្រប់រូបត្រូវតែធ្វើ គួរយកតម្រាប់តាមពោធិសត្វ។

ធម្មតា ព្រះពោធិសត្វទាំងឡាយ ទ្រង់តែងប្រព្រឹត្តប្រយោជន៍ចំពោះញាតិ មានការសង្គ្រោះញាតិជាដរាប សូម្បីទ្រង់ឋិតនៅក្នុងព្រះជាតិជាសត្វតិរច្ឆានក៏ដោយ ដូចមានរឿងដំណាលថា៖

កាលពីព្រេងនាយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាសុនខ មានហ្វូងនៃសុនខដ៏ធំជាបរិវារ អាស្រ័យនៅក្នុងព្រៃស្មសាន ។ ក្នុងកាលមួយ ព្រះរាជា ពារាណសី ទ្រង់យាងក្រសាលឧទ្យានពេញមួយថ្ងៃ លុះព្រះអាទិត្យអស្តង្គតហើយ ទើបទ្រង់គង់លើព្រះរាជរថត្រឡប់ទតកាន់រាជធានីវិញ។ ក្នុងពេលយប់នោះ ភ្លៀងបង្អុរចុះមកទទឹករាជរថ ដែលមនុស្សទាំងឡាយដាក់ក្នុងព្រះលានស្តេច។ ឆ្កែទាំងឡាយ ដែលរាជត្រកូលចិញ្ចឹមក៏ស៊ីនូវខ្សែជ្រាមស្បែកនៃរាជរថនោះអស់រលីង។ ព្រឹកឡើង ពួកមនុស្សទូលព្រះរាជាថា មានឆ្កែចូលតាមរន្ធលូ ហើយទំពារស៊ីខ្សែជ្រាមស្បែកនៃរាជរថ។ ព្រះរាជាទ្រង់ខ្ញាល់ ក៏បង្គាប់ឱ្យពិឃាតឆ្កែទាំងអស់ដែលប្រទះឃើញ ។ ពេលនោះមហាភ័យបានកើតឡើងដល់ហ្វូងឆ្កែទាំងឡាយ ។ ព្រះពោធិសត្វ មានសេចក្តី មេត្តាចង់សង្គ្រោះញាតិក៏ប្រថុយជីវិតសុខចិត្តចូលទៅគាល់ព្រះរាជាផ្ទាល់ខ្លួនហើយសួរដំណើររឿងនោះចំពោះព្រះរាជាថា៖ បពិត្រមហារាជ! ទ្រង់បញ្ជាការឱ្យពិឃាតឆ្កែទាំងអស់តាមតែប្រទះឬ? ឬលើកលែងពួកឆ្កែណាដែរ? លុះឮថា ព្រះរាជាលើកលែងឆ្កែក្នុងរាជត្រកូល ព្រះពោធិសត្វ ក៏ពោលថា បើដូច្នេះទ្រង់នឹងលុះក្នុងអគតិហើយ ការលុះក្នុងអគតិមិនគួរទេ មិនជារាជធម៌ទេធម្មតាស្តេច ត្រូវធ្វើឱ្យដូចជញ្ជីងថ្លឹងឱ្យស្មើជាដរាប ។ ព្រះរាជាទ្រង់សួរថា ម្នាលបណ្ឌិតអ្នកដឹងឬ ឆ្កែណាដែលស៊ីខ្សែជ្រាមស្បែក? ព្រះពោធិសត្វលុះត្រកូលព្រះរាជាថា ឆ្កែក្នុងខត្តិយត្រកូលស៊ីខ្សែនោះ ហើយក៏បង្គាប់ឱ្យគេតក្កះ និងស្មៅចិញ្ច្រៀនច្របាច់លាយគ្នា ពួតយកទឹកឱ្យឆ្កែទាំងនោះផឹក ។ ឆ្កែទាំងនោះក៏ក្អួតមកសុទ្ធតែខ្សែស្បែក ។

ព្រះរាជាទ្រង់សោមនស្សចំពោះព្យាករណ៍នោះទើបបូជា ព្រះពោធិសត្វ ដោយស្វេតច្ឆត្រ ព្រះពោធិសត្វសំដែងធម៌ហើយថ្វាយស្វេតច្ឆត្រដល់ព្រះរាជាទើបត្រឡប់ទៅកាន់កន្លែងរបស់ខ្លួនវិញ ។ ព្រះរាជាទ្រង់ប្រទានអភ័យដល់សត្វទាំងអស់ ផ្គត់ផ្គង់និច្ចភត្តដ៏មានតម្លៃ ដូចជាក្រយាស្ងោយរបស់ព្រះអង្គចំពោះសុនខទាំងឡាយ មានព្រះពោធិសត្វជាដើម។

ចំណែកខាងបុគ្គលណា ដែលប្រមូលទ្រព្យសម្បត្តិសន្សំទុកបានច្រើន មិនបរិភោគប្រើប្រាស់ខ្លួនឯងមិនសង្គ្រោះពពួកញាតិ បុគ្គលនោះលោកពោលថា ស្មើនឹងសត្វស្លាបឈ្មោះមយ្ហកៈ

សមដូចព្រះពោធិសត្វសំដែងធម៌ចំពោះមុខប្អូនរបស់លោក ដែលសម្លាប់បុត្ររបស់លោកព្រោះហេតុនៃទ្រព្យថា៖

បក្សីឈ្មោះមយ្ហកៈ ហើរទៅកាន់ដើមលៀបមានផ្លែទុំ ហើយគិតតែយំថា<<របស់អញៗ>> បក្សីឯទៀតមកដល់ហើយ ស៊ីផ្លែលៀបហើយហើរទៅវិញអស់ក្តី ក៏នៅតែកន្ទក់កន្ទេញថា <<របស់អញៗ>> ដដែល យ៉ាងណាមិញ បុគ្គលពួកខ្លះក្នុងលោកនេះ សន្សំទ្រព្យទុកបានច្រើន មិនហ៊ានចាយវាយប្រើប្រាស់ដោយខ្លួនឯង មិនគិតសង្គ្រោះនូវញាតិទាំងឡាយ កាលបុគ្គលនោះកំពុងហួងហែងរក្សា ទន្ទេញថា <<របស់អញៗ>> ស្រាប់តែពួករាជការ ឬចោរទាំងឡាយ មកកំហែងយកទ្រព្យនោះអស់រលីងទៅ ក៏នៅតែទន្ទេញថា<<របស់អញៗ>> ដដែល ដោយឥតប្រយោជន៍យ៉ាងនោះឯង ។

ចំណែកខាងបណ្ឌិតទាំងឡាយ មិនដូច្នោះឡើយ បើមានភោគសម្ប័ទហើយ លោកមិនសន្សំទុក គឺតែងសង្គ្រោះដល់ញាតិទាំឡាយ ហេតុនេះទើបលោកមានកិត្តិស័ព្ទពីរោះពីសាល្បីខ្ចរខ្ចាយទៅក្នុងលោកខាងមុខ ដូចន័យដែលបានសំដែងមកនេះឯង។ អាស្រ័យហេតុនេះហើយ បានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថាជា **ម្លប់ដ៏ត្រជាក់ ហៅថា ញាតិឆាយា** ។

## រាជាឆាយាទី៤.-

ពាក្យថា <<**រាជ** >> ប្រែថា << ស្តេច ព្រះរាជា ឬស្តេចគ្រងរាជ្យ ក្សត្រគ្រងរាជ្យ>> បើប្រែតាមរូបស័ព្ទថា << អ្នករុងរឿងដោយវិសេស ព្រោះមានតេជះក្រៃលែង ឬប្រែថា អ្នកញ៉ាំងប្រជាពលរដ្ឋឱ្យរីករាយ>> បានសេចក្តីថា អ្នកគ្រប់គ្រងប្រជានិករឱ្យមានស្វាមីភ័ក្តិចំពោះព្រះអង្គព្រោះព្រះអង្គមានសង្គហវត្ថុ៤ យ៉ាង គឺការឱ្យទេយ្យវត្ថុ ការពោលវាចាគួរឱ្យចង់ស្តាប់ ការប្រព្រឹត្តអំពើជាប្រយោជន៍ ការតាំងព្រះទ័យស្មើៗ គឺប្រើប្ញកពាឱ្យល្មមពេញចិត្តប្រជារាស្ត្រ ។

ព្រះរាជាព្រះអង្គតែងប្រកបដោយទសពិធរាជធម៌ គឺធម៌ទាំ១០ប្រការសំរាប់ស្តេចគ្រងរាជ្យ គឺ៖

**១.-ទាន** ទ្រង់ធ្វើព្រះរាជអំណោយ ។

**២.-សីល** ទ្រង់សមាទានសីល៥ សីល៨ និងសីល១០

**៣.-បរិច្ចាគ** ទ្រង់ចែកចាយទ្រង់ទំនុកបំរុងប្រទេស ។

**៤.-អាជ្ជវ** ទ្រង់មានហឫទ័យទៀងត្រង់ ។

**៥.-មទ្ទវ** ទ្រង់មានអធ្យាស្រ័យសុភាពរាបសារ ។

**៦.-តបៈ** ទ្រង់សមាទានឧបោសថ តាមកាលកំណត់ ។

**៧.-អក្កោធនៈ** ទ្រង់មិនដែលដុតកំដៅអ្នកដទៃ ។

**៨.-អវិហឹសា** ទ្រង់មិនដែលបៀតបៀនអ្នកដទៃ ។

**៩.-អវិរោធនៈ** ទ្រង់មិនដែលធ្វើអ្វីបំពារបំពានច្បាប់ ។

**១០.-ខន្តី** ទ្រង់មានព្រះទ័យអត់ធ្មត់ជានិច្ច ។

មិនតែប៉ុណ្ណោះសោត ព្រះអង្គតែងប្រកបដោយព្រហ្មវិហារធម៌៤ យ៉ាងទៀតគឺ៖

**១.-មេត្តា** ទ្រង់មានព្រះទ័យរាប់អានស្និទ្ធស្នាល ប្រាថ្នាឱ្យប្រជារាស្ត្រ បានសេចក្តីសុខចំរើន ។

**២.-ករុណា** ទ្រង់តែងមានព្រះទ័យអាណិតអាសូរ ចំពោះប្រជារាស្ត្រ ប្រាថ្នាឱ្យរួចចាកនូវសេចក្តីទុក្ខ ។

**៣.-មុទិតា** ទ្រង់មានព្រះទ័យរីករាយចំពោះប្រជារាស្ត្រដែលបានតាំងនៅក្នុងសេចក្តីសុខចំរើនហើយ

**៤.-ឧបេក្ខា** ទ្រង់ តែង តាំង ព្រះ ទ័យ ជា កណ្តាល។ ចំពោះ ប្រជា រាស្ត្រ ដែល បាន នូវ សេចក្តី សុខចំរើនហើយ ។

ព្រះរាជា ព្រះអង្គប្រកបដោយ មហាករុណាទិគុណ ចំពោះប្រជាពលករ និងគុណធម៌ ដូចបានសំដែងមកហើយនេះ ទើបព្រះអង្គមានព្រះនាមថា **រាជឆាយា ម្លប់គឺព្រះរាជា** ។

# សាសនឆាយាទី៥.-

ពាក្យថា << **សាសនៈ ឬសាសនា** >> ប្រែថា ពាក្យប្រៀនប្រដៅ ពាក្យទូន្មាន ឱវាទ ឬដំបូន្មាន។

ពាក្យថា<<**សាសនា**>> នេះប្រែបានច្រើនយ៉ាងទៀត ប្រែថា ពាក្យបណ្តាំ ពាក្យផ្តាំផ្ញើការប្រៀនប្រដៅ លទ្ធិ ពាក្យបង្គាប់ ការបង្គាប់បញ្ជា ដំណឹង សំបុត្រ ពាក្យប្រកាស ការប្រកាសប្រាប់ ការជឿស្តាប់ ការដាក់ទណ្ឌកម្ម ការកែសម្រួល ការគ្រប់គ្រង ការត្រួតត្រា ។

មូលហេតុដែលនាំឱ្យកើតមានសាសនាមាន៣យ៉ាងគឺ៖

១.-សេចក្តីភ័យខ្លាច

២.-ការខ្វះខាត

៣.- សេចក្តីត្រូវការ

បណ្តាចិត្តរបស់សត្វលោក គ្រប់ជាន់ថ្នាក់ គ្រប់វណ្ណៈ គ្រប់ប្រភេទ ទោះបីចេះក្តី ល្ងង់ក្តី តែងមានសេចក្តីតក់ស្លុតរន្ធត់ ចំពោះទុក្ខទោសគ្រប់យ៉ាង ដែលនាំឱ្យខ្លួននិងជីវិតខ្លួន ទទួលនូវគ្រោះថ្នាក់ជាហេតុឱ្យខំប្រឹងប្រែងស្វែងរកសរណៈ ជាទីពឹង ឱ្យជួយឃុំគ្រង ឱ្យកើតសេចក្តីសុខចំរើនការពារ ឬបណ្តោះបណ្តេ ទុក្ខទោស គ្រោះថ្នាក់គ្រប់យ៉ាង មិនឱ្យកើតមានដល់ខ្លួនឯង និងជីវិតរបស់ខ្លួនបាន ។

អាការដែលសត្វលោក ស្វែងរកទីពឹងនេះឯង ជាហេតុនាំឱ្យកើតមានវត្ថុស័ក្តិសិទ្ធិ សំរាប់រាប់អាន ធ្វើសក្ការគោរពបូជា ដើម្បីអំពាវនាវ ឬអង្វរករ សូមឱ្យវត្ថុស័ក្តិសិទ្ធិនោះជួយការពារនូវភយន្តរាយ ឬគ្រោះថ្នាក់ផ្សេងៗហើយសូមបណ្តាលឱ្យកើតសេចក្តីសុខចំរើនគ្រប់យ៉ាង ដោយមានជំនឿជឿជាក់ថាវត្ថុស័ក្តិសិទ្ធិ ដែលខ្លួនរាប់អាននោះ មានអំណាចខ្លាំងពូកែ អាចជួយជ្រោមជ្រែងស្ទួយខ្លួន និងជីវិតរបស់ខ្លួនឱ្យចាកផុតស្រឡះអំពីភយន្តរាយផ្សេងៗបានប្រាកដ ។ ការតក់ស្លុតខ្លាចរបស់សត្វលោកនេះឯង ជាមូលហេតុនាំឱ្យកើតលទ្ធិសាសនា ។

សត្វលោក ដែលកើតមកអាស្រ័យ នៅក្នុងលោក តាមទំនើងឯកឯងមិនបាន ត្រូវតែពឹងពាក់អាស្រ័យនូវគ្នានិងគ្នា ការដែលពឹងពាក់អាស្រ័យគ្នានោះ ជាសេចក្តីត្រូវការដំបូងបំផុតដែលនាំឱ្យសត្វលោក នៅរួបរួមគ្នាជាពួកជាក្រុម ។ ក៏សត្វលោកដែលនៅរួមគ្នា ជាពួកគណៈយ៉ាងនេះ រមែងមានអធ្យាស្រ័យ ចិត្តគំនិតគ្រោតគ្រាត និងល្អិតល្អផ្សេងៗពីគ្នាជាធម្មតា រមែងពិចារណាឃើញថា ការដែលនៅរួមសាមគ្គីជាមួយគ្នាល្អវិសេស ជាជាងនៅបែកខ្ញែក ចេញដាច់ដោយឡែកពីគ្នា មានមេត្តាត្រាប្រណីអត់ឱនដល់គ្នា ល្អជាជាង ការប្រណាំងប្រជែងដណ្តើមដៃ ឬដណ្តើមវាសនាគ្នា ការប្រព្រឹត្តអាក្រក់មានកាប់សម្លាប់ លួចប្លន់ កុហកឆបោក បៀតបៀនយោរយៅដល់គ្នា ក៏គ្មាននរណាគាប់ចិត្ត ឬត្រូវអធ្យាស្រ័យទេ គួរតែមានច្បាប់សំរាប់ចង្អុលបង្ហាញប្រាប់ការខុសត្រូវ គុណទោស អាក្រក់ល្អ យ៉ាងនេះជាដើមទើបល្អ ម្ល៉ោះហើយសត្វលោកក៏ប្រជុំគ្នាតាំងពីច្បាប់ឡើង ជាទំនៀមទម្លាប់ ហើយនាំគ្នាកាន់ប្រព្រឹត្តប្រតិបត្តិ ដើម្បីសេចក្តីសុខចំរើនដល់ពួកគណៈ ។ ច្បាប់ឬលទ្ធិប្រពៃណីនេះ កាលបើមានកម្លាំងខ្លាំងក្លា ពូកែ ស័ក្តិសិទ្ធិច្រើន ក៏កើតមានទៅជាលទ្ធិសាសនាឡើង ។ សេចក្តីត្រូវការនេះឯង ជាមូលហេតុនាំឱ្យកើតលទ្ធិសាសនា ។

ធម្មតាសត្វលោក ដែលខ្សត់ខ្សោយ ក្រលំបាក កាលបើបានទទួលសេចក្តីសុខស្រួល ឬចំរុងចំរើនដល់ខ្លួន អំពីវត្ថុណាៗ រមែងនិយមរាប់អាន ហើយឈោងយកវត្ថុនោះៗ ហើយតែងទទួលរាប់អានវត្ថុនោះៗ ថាជាទីពឹង កាលបើស្រឡាញ់ជាប់ចិត្តគំនិតទៅលើវត្ថុណាៗហើយ តែងទទួលរាប់អានវត្ថុនោះៗ ថាជារបស់ខ្ពង់ខ្ពស់ គួរដល់សក្ការបូជា គោរព តទៅ ។ ដោយមូលហេតុនេះហើយ សេចក្តីខ្វះខាតមិនគ្រប់គ្រាន់ទើបចាត់ជាមូលហេតុ នាំឱ្យកើតលទ្ធិសសានាមួយដែរ ។

# សាសនាមាន២ យ៉ាងគឺ៖

១.- សសានាអង្វរការបាន

២.- សាសនាអង្វរករមិនបាន ។

សាសនាដែលអង្វរករបាន បានដល់ពាហិរសាសនាជាសាសនាខាងក្រៅអំពីពុទ្ធសាសនា។ សាសនា ដែលអង្វរករ មិនបាន។ ដល់ពុទ្ធសាសនា ជាសាសនាប្រដៅមនុស្ស ឱ្យជឿកម្មផល និងផលរបស់កម្ម ។

ពុទ្ធសសានា គឺជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ព្រះឱវាទានុសាសនី គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ វិចិត្រពិស្ដារដោយហេតុ ដែលព្រះអង្គសំដែងអនុលោមទៅតាមចរិតនិស្ស័យវាសនា តាមសតិបញ្ញារបស់វេនេយ្យសត្វ និងតាមកាលសម័យ តាមប្រទេសខ្លះ ហៅថាពុទ្ធសាសនា ប្រែថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ឬរបស់អ្នកភ្ញាក់រលឹកគឺភ្ញាក់ពីសេចក្ដីល្ងង់ពោលគឺអវិជ្ជា ។

បានសេចក្ដីថា << ពាក្យប្រៀនប្រដៅរបស់អ្នកភ្ញាក់ កំណើតកើតគំនិត ឬថា ពាក្យប្រៀនប្រដៅជាហេតុឱ្យអ្នកកាន់តាមភ្ញាក់កំណើតកើតគំនិត>> ដូច្នេះវិញក៏បាន ។

# ការប្រៀបធៀបសាសនា

មែនពិត! ពុទ្ធសាសនា មានតម្លៃយ៉ាងឯកជាងពាហិរសាសនា ព្រោះអ្វី? ព្រោះថា ព្រះពុទ្ធសាសនាអាចឱ្យអានិសង្សដល់អ្នកដែលប្រតិបត្តិត្រឹមត្រូវ ឱ្យរលាស់ខ្លួនចេញចាកភពទាំង៣ បាន គឺលើកស្ទួយឱ្យដល់កន្លែងដែលមិនមានកើតស្លាប់ពោលគឺព្រះនិព្វាន ។

ឯពាហិរសាសនា ជាសាសនា មិនអាចនឹងយឹតយោងឬស្រោចស្រង់អ្នកប្រតិបត្តិឱ្យដល់ព្រះនិព្វាន ដែលជាទីរំលត់ទុក្ខបានឡើយ បើទុកជាពាហិរសាសនា ដែលខំប្រព្រឹត្តប្រតិបត្តិត្រឹមត្រូវល្មមសមគួរ តួយ៉ាងដូចជាសាសនារបស់តាបសឥសីជាដើមនោះ ក៏មិនអាចយឹតយោងសណ្ដោងខ្លួនឱ្យបានដល់ព្រះនិព្វានបានសោះឡើយ បើយ៉ាងវិសេសណាស់បានតែត្រឹមញ៉ាំងអ្នកប្រតិបត្តិឱ្យបានកើតក្នុងព្រហ្មលោកប៉ុណ្ណោះ ។

# ប្រភេទរបស់ពុទ្ធសាសនា

ព្រះពុទ្ធសាសនាមាន៣យ៉ាងគឺ៖

**១.- យថានុលោមសាសនា** ពាក្យប្រៀនប្រដៅដែលព្រះអង្គសំដែងអនុលោមតាមអធ្យាស្រ័យ និងនិស្ស័យវាសនារបស់សត្វបានដល់ព្រះសូត្រ ។

**២.- យថាបរាធសាសនា** ពាក្យប្រៀនប្រដៅ ដែលព្រះអង្គសំដែងទៅតាមទោសកំហុសរបស់សត្វ បានដល់ព្រះវិន័យ ។

**៣.- យថាធម្មទេសនា** ពាក្យប្រៀនប្រដៅ ដែលព្រះអង្គសំដែងទៅតាមគួរតាមធម៌ បានដល់ព្រះអភិធម្ម ។

## ព្រះឱវាទានុសាសនី

ព្រះពុទ្ធសាសនា ចែកចេញជា៣យ៉ាងទៀតគឺឱវាទានុសាសនី៖

**១.-សព្វបាបស្សអករណំ** ទ្រង់ហាមមិនឱ្យធ្វើបាបទាំងពួងបានដល់សីល ។

**២.-កុសលស្សូបសម្បទា** ទ្រង់ប្រដៅឱ្យបំពេញកុសល សំដៅយកសមាធិ ។

**៣.-សចិត្តបរិយោទបនំ** ទ្រង់ប្រដៅឱ្យជំរះដុសខាត់ចិត្តឱ្យបានស្អាតផូរផង់ សំដៅយកបញ្ញា ។

# ប្រភេទនៃពុទ្ធវចនះ

ប្រភេទនៃពុទ្ធវចនះ មាន១យ៉ាងក៏មាន ២យ៉ាងក៏មាន ៣យ៉ាងក៏មាន ៥ យ៉ាងក៏មាន ៩ យ៉ាងក៏មាន ។ ដែលពោលថាមានតែ១នោះ បានដល់វិមុទត្តិរស គឺព្រះនិព្វាន ឬដៅដល់អប្បមាទះ ។ ដែលមាន២នោះ បានដល់ព្រះធម៌និងព្រះវិន័យ។ ព្រះពុទ្ធសាសនានេះ បើសំដែងដោយពិស្តារមានដល់ទៅប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធ(៨៤០០០)។ បើរួមឱ្យខ្លី ចុះមកមាន៣យ៉ាងក៏មាន ២យ៉ាងក៏មាន មាន៣យ៉ាង បានដល់ព្រះឱវាទានុសាសនីទាំង៣ ដូចបានសំដែងរួចមកហើយ ឬបានដល់បិដកទាំង៣គឺព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ។

**មាន២យ៉ាងនោះគឺ៖**

១.-ទ្រង់ប្រដៅឱ្យលះបង់នូវសេចក្ដីប្រមាទ ពាក្យថា បមាទះ ប្រែថា សេចក្ដីធ្វេសប្រហែស មានកិរិយាភ្លាំងភ្លាត់ភ្លេចស្មារតី ឬការបណ្ដែតបណ្ដោយស្មារតីជាលក្ខណៈបមាទះ នេះជាកំពូលនៃអកុសលធម៌ទាំពួង ។

២.-ទ្រង់ប្រដៅឱ្យចំរើននូវអប្បមាទធម៌ ពាក្យថា អប្បមាទះ ប្រែថា ការមិនធ្វេសប្រហែស ការប្រុងប្រយ័ត្នមានកិរិយា មិនភ្លាំងស្មារតី ឬមិនបណ្ដែតបណ្ដោយស្មារតី ជាលក្ខណៈ អប្បមាទះ ជាកំពូលនៃកុសលធម៌ទាំពួង ។

មាន២យ៉ាងទៀតគឺធម៌១ វិន័យ១ ព្រះវិន័យបិដតទាំងមូលហៅថាវិន័យ ក្រៅពីនោះហៅថាធម៌ទាំងអស់ សមដូចពុទ្ធដីកាថា

**យោ ខោ អានន្ទ មយា ធម្មោ ច វិនយោ ច**

**ទេសិតោ បញ្ញត្តោ សោ ខោ មមច្ចយេន សត្ថា**

ប្រែថា៖ ម្នាលអានន្ទធម៌ឯណាដែលតថាគតបានបញ្ញត្តហើយក្ដី វិន័យឯណាដែលតថាគតបានបញ្ញត្តហើយក្ដី ធម៌និងវិន័យនោះ លុះអំណើសឥតអំពីតថាគតទៅ នឹងបានជាគ្រូអាចារ្យប្រៀនប្រដៅអ្នករាល់គ្នា។

**មាន៣យ៉ាងនោះគឺ៖**

**១.-បរិយត្តិសាសនា** បានដល់ធម្មក្ខន្ធទាំង ៨៤០០០ដែលមានមកក្នុងបិដកទាំង៣ ។

**២.-បដិបត្តិសាសនា** បានដល់សេចក្ដីប្រតិបត្តិតាម ។

**៣.-បដិវេធសាសនា** បានដល់ការត្រាស់ដឹងនូវមគ្គនិងផល ។

មាន៥យ៉ាងនោះគឺចែកតាមនិកាយ

**១.-ទីឃនិកាយ** មាន( ៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម)
**២.-មជ្ឈិមនិកាយ**(១៥២ សូត្រមានមូលបរិយាយសូត្រជាដើម)
**៣.-សំយុត្តនិកាយ**(៧៧៦២ សូត្រមានឱឃតរណសូត្រជាដើម)
**៤.-អង្គុត្តនិកាយ**( ៩៥៥៧ សូត្រមានចិត្តបរិយាយសូត្រជាដើម)
**៥.-ខុទ្ទកនិកាយ** ចែកជា១៥ គម្ពីរគឺ៖

១.ខុទ្ទកបាឋ; ២.ធម្មបទ; ៣.ឧទាន; ៤.ឥតិវុត្តបាត; ៥.សុត្តនិបាត; ៦.វិមានវត្ថុ; ៧.បេតវត្ថុ; ៨.ថេរគាថា; ៩.ថេរីគាថា; ១០.ជាតក; ១១.និទ្ទេស; ១២.បដិសម្ភិទា; ១៣.អបទាន; ១៤.ពុទ្ធវំស; ១៥.ចរិយាបិដក ។

ដែលចែកជា៩ នោះ បានដល់ព្រះនព្វលោកុត្តរធម៌៩ គឺ មគ្គ៤ ផល៤ និព្វាន១ មគ្គមាន សោតាបត្តិមគ្គជាដើម ផលមានសោតាបត្តិផលជាដើម ។

បើចែកជាវចនៈ មាន៣ទៀតគឺ៖

**១.-បឋមពុទ្ធវចនៈ** បានដល់ពុទ្ធដីកា ដែលទ្រង់មានព្រះបន្ទូលជាដំបូង សំដៅយកឧទានវាចា ដែលទ្រង់បន្លឺឡើងដោយសោមនស្សញ្ញាណ មានបទថាអនេកជាតិសំសារំ ជាដើម ។

**២.-មជ្ឈិមពុទ្ធវចនៈ** បានដល់ពុទ្ធដីកាដែលទ្រង់ត្រាស់ជាចន្លោះកណ្តាលនៃវចនៈទាំងពីរគឺបឋម ពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ។

**៣.-បច្ឆិមពុទ្ធវចនៈ** បានដល់ពុទ្ធដីកាដែលទ្រង់ផ្តែផ្តាំ ក្នុងកាលជិតបរិនិព្វានថា៖ ហន្ទទានិ ភិក្ខវេ អាមន្តយាមិវោ ភិក្ខវេ ខយវយធម្មា សង្ខារា អប្បមាទេន សម្បាទេថ ប្រែថា ម្នាលភិក្ខុទាំងឡាយ ម្តងនេះតថាគតផ្តាំអ្នករាល់គ្នា ជាពៅបំផុត សង្ខារទាំងឡាយមានការវិនាសសាបសូន្យជាធម្មតា អ្នករាល់គ្នាត្រូវកុំភ្លេចខ្លួន កុំទ្វេសប្រហែសឱ្យសោះ ។

បើចែកជាទេសនាមាន៣ យ៉ាងគឺ៖

**១.-អាណាទេសនា** បានដល់ព្រះវិន័យបិដក ព្រោះព្រះវិន័យព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងដោយ អាជ្ញា គឺបញ្ញត្តិអំពីការខុសត្រូវ ជាច្បាប់មានកម្រិតពិតប្រាកដ ។

**២.-វោហារទេសនា** បានដល់ព្រះសូត្រ ព្រោះព្រះអង្គសំដែងដោយវោហារហេតុ ព្រះអង្គប៉ិនស្រប់ ក្នុងពិធីបញ្ចុះបញ្ចូលនិយមតាមអធ្យាស្រ័យនិស្ស័យរបស់សត្វ ។

**៣.-បរមត្ថទេសនា** បានដល់ព្រះអភិធម្មបិដក ព្រោះព្រះអភិធម្ម ព្រះអង្គសំដែងដោយបរមត្ថ មាន អត្ថន័យដ៏ជ្រាលជ្រៅ គម្ភីរភាព មានចិត្តនិងចេតសិកជាដើម ព្រោះព្រះអង្គឈ្លាសវៃក្នុងប្រយោជន៍ ដ៏ឧត្តម ។

ពុទ្ធវចនៈ បើចែកជា កថា មាន៣ យ៉ាងគឺ៖

**១.-សំវរាសំវរកថា** ព្រះពុទ្ធដីកាសំដែងអំពីសង្រ្គម ដែលជាទំនាស់ ជាសត្រូវដល់អជ្ឈាចារ គឺការ ប្រព្រឹត្តិខុសច្បាប់ ឬមារយាទអាក្រក់ បានដល់វិន័យបិដក។

**២.-ទិដ្ឋិវិនិវេឋនកថា** ព្រះពុទ្ធដីកាសំដែងអំពីការលះបង់នូវទិដ្ឋិដែលជាបដិបក្ខ ដល់ទិដ្ឋិ៦២ បានដល់សុត្តន្តបិដក ។

**៣.-នាមរូបបរិច្ឆេទកថា** ព្រះពុទ្ធដីកាសំដែងអំពីការកំណត់នូវនាមនិងរូបដែលជាបដិបក្ខ ដល់កិលេស មានរាគៈ ជាដើម បានដល់អភិធម្មបិដក។

ពុទ្ធវចនៈ បើចែកជា សិក្ខាវិញ មាន៣យ៉ាង គឺ៖

**១.-អធិសីលសិក្ខា** ការសិក្សាខាងអធិសីល បានដល់វិន័យបិដក

**២.-អធិចត្តសិក្ខា** ការសិក្សាខាងផ្លូវសមាធិចិត្ត បានដល់សុតន្តបិដក

**៣.-អធិប្បញ្ញាសិក្ខា** ការសិក្សាខាងផ្លូវអធិប្បញ្ញា បានដល់អភិធម្មបិដក។

បើចែកជា បិដកវិញ មាន៣គឺ៖

**១.-វិនយបិដក** មាន២១០០០ធម្មក្ខន្ធ

**២.-សុតន្តបិដក** មាន២១០០០ធម្មក្ខន្ធ

**៣.-អភិធម្មបិដក** មាន៤២០០០ធម្មក្ខន្ធ

ច្បាប់ក្នុងពុទ្ធសាសនា បើសំដែងដោយសង្ខេប បានដល់បំណងរបស់ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ ដែលទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ទ្រង់ប្រាថ្នានឹងបំភ្លឺលោក ឱ្យភ្លឺច្បាស់ នូវប្រយោជន៍គ្រប់យ៉ាងទើបទ្រង់ប្រកាសច្បាប់ទាំង៣យ៉ាងគឺ ព្រះសូត្រ១ ព្រះវិន័យ១ ព្រះអភិធម្ម១។

**១.-ព្រះវិន័យ** ជាកិច្ចហាមប្រាមកាយនិងវាចា មិនឱ្យប្រព្រឹត្តល្មើសក្នុងសិក្ខាបទតូចធំ ជាគ្រឿងការពារ មិនឱ្យមានការបៀតបៀន ឈ្លោះទាស់ទែងខ្វែងយោបល់គ្នា ដើម្បីរក្សាកិរិយាមារយាទ ឱ្យមានរបៀបរៀបរយល្អ ។

**២.-ព្រះសូត្រ** ជាច្បាប់ហាត់ពត់នូវអធ្យាស្រ័យឱ្យរឹងរឹតតែល្អវិសេសវិសាលឡើងទៀត ដោយផ្សាយមេត្តាចិត្តចេះស្រឡាញ់រាប់អានគ្នា ដើម្បីឱ្យមានសាមគ្គីព្រមព្រៀងគ្នា ស្មោះស្មើដល់គ្នា ។

**៣.-ព្រះអភិធម្ម** ជាច្បាប់ដុសខាត់ចិត្ត លុបលាងជំរះសន្តានចិត្ត ដើម្បីត្រាស់ដឹងនូវមគ្គនិងផល ឬជាគ្រឿងបំបែករូបធាតុ មានវិញ្ញាណធាតុជាដើម ឱ្យឃើញជាក់ស្តែងដល់ចិត្ត ដើម្បីនិងសម្ពន្ធចងធាតុផ្សំផ្គុំលាយគ្នា ប្រើការផ្សេងៗ ឱ្យសំរេចតាមបំណងរបស់អ្នកឆ្លៀវឆ្លាស ប្រតិពលយល់ក្នុងធាតុហៅថា ធាតុកោសល ។

ពុទ្ធសាសនាបើសំដែងដោយអង្គ មាន៩ យ៉ាងគឺ៖

**១.-សុត្តៈ** លោកសង្គ្រោះយក ឧភតោវិភង្គ គឺភិក្ខុវិភង្គ១ ភិក្ខុនីវិភង្គ១ និងនិទ្ទេសដែលជាភាជនីយ គឺសេចក្តីអធិប្បាយវែកញែកពាក្យបញ្ញត្ត ក្នុងវិភង្គទាំងពីរនោះនិងខន្ធកៈ និងបរិវារជាដើមផង យកមង្គលសូត្រ និងរតនៈសូត្រជាដើមផង យកជាពុទ្ធវចនៈដទៃ ដែលឈ្មោះថាសុតន្តៈផង ។

**២.-គេយ្យៈ** លោកសង្គ្រោះយកសូត្រ ដែលប្រកបដោយគាថា ឬសគាថវគ្គទាំងអស់ក្នុងសំយុត្តនិកាយ ។

**៣.-វេយ្យាករណៈ** សំដៅយកអភិធម្មបិដកទាំអស់ និងសូត្រដែលមិនលាយដោយគាថា ។

**៤.-គាថា** សំដៅយកធម្មបទ ថេរគាថា ឬពាក្យដែលជាគាថាសុទ្ធ ។

**៥.-ឧទានៈ** គឺ លាន់ព្រះវាចា ដែលព្រះអង្គទ្រង់ជ្រាបហេតុអ្វីម្យ៉ាងហើយទ្រង់បន្លឺឡើង យកសង្គ្រោះ យកសូត្រ៨២ ដែលប្រកបដោយគាថា អាស្រ័យដោយយកសោមនស្សញ្ញាណ ។

**៦.-ឥតិវុត្តកៈ** សូត្រដែលពួកសាវ័ក លោកសំដែងអាងដល់ព្រះពុទ្ធដីកាជាបន្ទាល់ ដែលមានជាប់បាលីថា<<**វុត្តញ្ចេតំ ភគវា** >> ដូច្នេះជាដើម លោកសង្គ្រោះយកសូត្រ១១០សូត្រ ។

**៧.-ជាតកៈ** ជារឿងដែលសំដែងដោយជាតិដែលកន្លងទៅហើយក្នុងភពមុនៗ សំដៅយកជាតក ៥៥០ជាតិមានអបណ្ណកជាតកជាដើម ។

**៨.-អព្ភូតធម្មៈ** ជាធម៌ដែលទ្រង់សំដែងជាប់ពាក្យថា៖ មិនដែលកើតឡើងហើយ កើតឡើងបានថាគួរអស្ចារ្យ គួរស្ងើច ដូចព្រះសូត្រដែលមានបទបាលីថា៖

**ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភូតធម្មា អានន្ទេ**

ប្រែថា ម្នាលភិក្ខុទាំងឡាយ អច្ឆរិយអព្ភូតធម៌៤ យ៉ាងនេះមានក្នុងអានន្ទ ដូច្នេះជាដើម ។

**៩.-វេទល្លៈ** ពួកសូត្រដែលអ្នកសួរហើយ បានចេះដឹងនិងសេចក្តីត្រេកអរជ្រះថ្លា សប្បាយចិត្ត មានចុល្លវេទសូត្រនិងមហាវេទល្លសូត្រជាដើម ហៅថា វេទល្លៈ ។

ពុទ្ធសាសនា បើសំដែងអំពីល្អមាន៣យ៉ាងគឺ៖

**១.-អាទិកល្យាណំ** លំអខាងដើមបានដល់សីល ។

**២.-មជ្ឈេកល្យាណំ** លំអត្រង់កណ្តាលបានដល់សមាធិ ។

**៣.-បរិយោសានកល្យាណំ** លំអខាងចុង បានដល់បញ្ញា ។

ពុទ្ធសាសនា មានធុរៈពីរយ៉ាងគឺ៖

**១.-គន្ថធុរៈ** បានដល់ការសិក្សារៀនសូត្រក្នុងព្រះត្រៃបិដក គឺព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម ឬក៏ដូចជាការសិក្សានូវព្រះបរិយត្តិ សព្វថ្ងៃនេះ ហៅថា គន្ថធុរៈ ។

**២.-វិបស្សនាធុរៈ** បានដល់ការភាវនា ចំរើនវិបស្សនាកម្មដ្ឋានក្នុងទីស្ងប់ស្ងាត់តែម្នាក់ឯង ។ ពុទ្ធសាសនានេះ បើអ្នកព្យាយាមខំប្រឹងប្រែងប្រព្រឹត្តប្រតិបត្តិដល់កំរិត ដល់ថ្នាក់ទាំង៣ គឺ សីល សមាធិ បញ្ញា ណាមួយហើយ អាចនឹងហុចប្រយោជន៍ ឱ្យប្លែកគ្នាយ៉ាងនេះ៖

សីល ញ៉ាំងអ្នកប្រតិបត្តិតាមឱ្យ បានវិជ្ជា៣<br>
សមាធិឱ្យ បាននូវអភិញ្ញា៦<br>
បញ្ញា ឱ្យ បាននូវបដិសម្ភិទា៤ ។

សីល ញ៉ាំងអ្នកប្រតិបត្តិតាមឱ្យ វៀរបង់នូវកាមសុខល្លិកានុយោគ បាន
សមាធិឱ្យ វៀរបង់នូវអត្តកិលមថានុយោគ បាន
បញ្ញាឱ្យ សេពនូវ មជ្ឈិមបដិបទា បាន ។

សីល ញ៉ាំងអ្នកប្រតិបត្តិតាមឱ្យ កន្លងផុតនូវអបាយភូមិ បាន
សមាធិ ឱ្យ កន្លងនូវកាមធាតុ បាន
បញ្ញាឱ្យ កន្លងនូវភពទាំងអស់ បាន ។

សីល ញ៉ាំងអ្នកប្រតិបត្តិតាមឱ្យ លះបង់នូវកិលេសដោយតទង្គប្បហាន
សមាធិឱ្យ លះបង់នូវកិលេសដោយវិក្ខម្ភនប្បហាន
បញ្ញា ឱ្យ លះបង់នូវកិលេស បាន ដោយសមុច្ឆេទប្បហាន ។

សីល ញ៉ាំងអ្នកប្រតិបត្តិតាមឱ្យ ផ្ចាញ់នូវ វីតិក្កមទោសនៃកិលេសទាំងឡាយ បាន ( ទោសកំហុស ដែលកិលេសយ៉ាងគ្រោតគ្រាត បណ្តាលឱ្យ ប្រព្រឹត្តកន្លងក្នុងទ្វារទាំង៣)
សមាធិឱ្យ ផ្ចាញ់នូវ បរិយុដ្ឋាន នៃកិលេសទាំងឡាយ បាន ( កិរិយាដែលកិលេស យ៉ាងកណ្តាលគ្របសង្កត់នូវកុសលចិត្តទុកមិនឱ្យ ប្រព្រឹត្តទៅ បាន)
បញ្ញា ឱ្យ ផ្ចាញ់នូវអនុសយកិលេសទាំងឡាយ បាន ( កិរិយាដែលកិលេស យ៉ាង ល្អិត តាម ដេក ត្រាំ នៅក្នុងចិត្ត ទន្ទឹងចាំមានបច្ច័យគួរកើតឡើង បាន ក៏កើតឡើង) ។

សីល ញ៉ាំងអ្នកប្រតិបត្តិតាមឱ្យ ជម្រះនូវសង្កិលេសធម៌ គឺទុច្ចរិតទាំង៣ បាន
សមាធិឱ្យ ជម្រះនូវសង្កិលេសធម៌គឺតណ្ហា បាន
បញ្ញាឱ្យ ជម្រះនូវសង្កិលេសធម៌ គឺទិដ្ឋិ បាន ។

សីល ញ៉ាំងអ្នកប្រតិបត្តិតាមឱ្យ ដល់នូវភាពជាសោតាបន្នបុគ្គលនិងសកទាគាមិបុគ្គល បាន
សមាធិ ឱ្យ ដល់នូវភាពជាអនាគាមិបុគ្គល បាន
បញ្ញាឱ្យ ដល់នូវភាពជាព្រះអរហន្ត បាន ។

ពុទ្ធសាសនា បដិសេធ សេចក្តីប្រតិបត្តិ ២ យ៉ាងគឺ៖

១.-**កាមសុខល្លិកានុយោគ** ការប្រកបខ្លួនឱ្យ ជាប់ជំពាក់ដោយសេចក្តីសុខក្នុងកាមទាំងឡាយ ។

**២.-អត្តកិលមថានុយោគ** ការប្រកបសេចក្តីលំបាកដល់ខ្លួនឱ្យហត់នឿយឥតប្រយោជន៍ ដោយពុទ្ធដីកាថា៖ <<**ទ្វេ មេ ភិក្ខវេ អនតា បព្វជិតេន ន សេវិតព្វា**>> ម្នាលភិក្ខុទាំងឡាយ! សេចក្តីប្រតិបត្តិដ៏លាមក ទាំងពីរយ៉ាងនេះ បព្វជិតមិនត្រូវសេព គឺថាមិនត្រូវប្រតិបត្តិឡើយ ព្រោះជាសេចក្តីប្រតិបត្តិថោកទាប ជារបស់បុថុជ្ជន មិនមែនជារបស់អរិយបុគ្គល ទាំងមិនមែនជាសេចក្តីប្រតិបត្តិ ប្រកបដោយប្រយោជន៍ឡើយ ។

ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រកាសសេចក្តី ប្រតិបត្តិជាកណ្តាលគឺធម៌ដែលគួរត្រាស់ដឹង មានអង្គ៨ ហៅថាអដ្ឋង្គិកមគ្គ ជាគ្រឿងចេញផុតចាកកិលេស ។

អដ្ឋង្គិកមគ្គ ធម៌ប្រកបដោយអង្គ៨ គឺ៖

**១.-សម្មាទិដ្ឋិ** ប្រាជ្ញាយល់ត្រូវ

**២.-សម្មាសង្កប្បោ** សេចក្តីត្រិះរិះត្រូវ

**៣.-សម្មាវាចា** សម្តីត្រូវ

**៤.-សម្មាកម្មន្តោ** ការងារត្រូវ

**៥.-សម្មាអាជីវោ** ចិញ្ចឹមជីវិតត្រូវ

**៦.-សម្មាវាយាមោ** ព្យាយាមត្រូវ

**៧.-សម្មាសតិ** សេចក្តីរលឹកត្រូវ

**៨.-សម្មាសមាធិ** កិរិយាដំកល់ចិត្តឱ្យនឹងត្រូវ ។

ដោយព្រះពុទ្ធដីកាបញ្ជាក់ថា ÷ << **ឯតេ តេ ខោ ភិក្ខវេ ឧភោ អន្តេ អនុបកម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា**>> ប្រែថា នេះនៃ! ភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិជាកណ្តាលមិនលាយ ច្រឡំដោយសេចក្តីប្រតិបត្តិដ៏លាមក អាក្រក់ទាំងពីរ យ៉ាងនោះ តថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញា ឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ ប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់ ដើម្បីសេចក្តីដឹងក្រៃលែង ដើម្បីសេចក្តីដឹងល្អ ដើម្បីសេចក្តីរលត់ទុក្ខ ពោលគឺព្រះនិព្វន ។

ពុទ្ធសាសនារុងរឿងបានដោយហេតុ៥ យ៉ាងគឺ៖

**១.-សក្កច្ចំ ធម្មំ សុណន្តិ** បរិស័ទទាំង៤ ស្តាប់ធម៌ដោយគោរព ។

**២.-សក្កច្ចំ ធម្មំ បរិយាបុណន្តិ** បរិស័ទទាំង៤ រៀនធម៌ដោយគោរព ។

**៣.-សក្កច្ចំ ធម្មំ ធារេន្តិ** បរិស័ទទាំង៤ ទ្រទ្រង់ធម៌ដោយគោរព ។

**៤.-សក្កច្ចំ ធាតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ** បរិស័ទទាំង៤ ពិចារណានូវសេចក្តីនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយដោយគោរព គឺដឹងសេចក្តីអធិប្បាយនៃធម៌ នោះដោយយកចិត្តទុកដាក់ ។

**៥.-សក្កច្ចំ ធម្មានំ អត្ថមញ្ញា បដិបជ្ជន្តិ** បរិស័ទទាំង៤ ដឹងសេចក្តីអធិប្បាយនៃធម៌ ហើយប្រតិបត្តិតាមធម៌ដោយគោរព ។

ពុទ្ធសាសនាសាបសូន្យដោយហេតុ៥ យ៉ាងគឺ៖

**១.-នសក្កច្ចំ ធម្មំ សុណន្តិ** បរិស័ទទាំង៤ មិនស្តាប់ធម៌ដោយគោរព ។

**២.-នសក្កច្ចំ ធម្មំ បរិយាបុណន្តិ** បរិស័ទទាំង៤ មិនរៀនធម៌ដោយគោរព ។

**៣.-នសក្កច្ចំ ធម្មំ ធារេន្តិ** បរិស័ទទាំង៤ មិនទ្រទ្រង់ធម៌ដោយគោរព ។

**៤.-នសក្កច្ចំ ធាតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ** បរិស័ទទាំង៤ មិនពិចារណានូវសេចក្តីនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយដោយគោរព គឺដឹងសេចក្តីអធិប្បាយនៃធម៌ នោះដោយយកចិត្តទុកដាក់ ។

**៥.-នសក្កច្ចំ ធម្មានំ អត្ថមញ្ញា បដិបជ្ជន្តិ** បរិស័ទទាំង៤ មិនដឹងសេចក្តីអធិប្បាយនៃធម៌ ហើយប្រតិបត្តិតាមធម៌ដោយគោរព ។

ពុទ្ធសាសនាសាបសូន្យមាន៦ លើកគឺ៖

លើកទី១. សាសនាកន្លងទៅបាន ៥០៩ ឆ្នាំ បាត់អស់ភិក្ខុនី

លើកទី២. សាសនាកន្លងទៅបាន ១០០០ ឆ្នាំ បាត់អស់ព្រះអរហន្ត

លើកទី៣. សាសនាកន្លងទៅបាន២០០០ ឆ្នាំ បាត់អស់ភក្ខុទ្រទ្រង់ព្រះត្រៃបិដក ចាំមាត់ទទេ ទាំងមានភិក្ខុអលជ្ជី កើតឡើងច្រើនមានលេងចត្រង្គ និងល្បែងភ្នាល់គ្នាជាដើម ។

លើកទី៤. សាសនាកន្លងទៅបាន ៣០០០ ឆ្នាំអស់ភិក្ខុធ្វើឧបោសថកម្ម ។

លើកទី៥. សាសនាកន្លងទៅបាន ៤០០០ ឆ្នាំភិក្ខុទ្រទ្រង់ចីវរ មិនគ្រប់ត្រៃ៣ ។

លើកទី៦. សាសនាកន្លងទៅបាន ៥០០០ ឆ្នាំ ភិក្ខុទ្រទ្រង់កំណាត់សំពត់លឿង មានចងដៃនិងសៀតត្រចៀកជាទីបំផុត មានភរិយាធ្វើស្រែចំការ លក់ដូរដូចគ្រហស្ថ ហៅថា<< គោត្រភូសង្ឃ>> ដល់គ្រប់៥០០០ឆ្នាំ ភេទសង្ឃ ក៏អស់ មិនប្រាកដក្នុងជម្ពូទ្វីព ។

ពុទ្ធសាសនាអន្តរធានមាន៥ យ៉ាងគឺ៖

**១.-បរិយត្តិអន្តរធាន** មិនមានអ្នកទ្រទ្រង់ព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម ។

**២.-បដិបត្តិអន្តរធាន** មិនមានអ្នកប្រតិបត្តិសីល សមាធិ បញ្ញា ។

**៣.-បដិវេធអន្តរធាន** មិនមានអ្នកត្រាស់ដឹងនូវមគ្គនិងផល ។

**៤.-លិង្គអន្តរធាន** ភេទសង្ឃមិនមានប្រាកដនៅក្នុងជម្ពូទ្វីពឡើយ ។

**៥.-ធាតុអន្តរធាន** ព្រះធាតុសូន្យអស់រលីងគ្មានសល់ ។

ពុទ្ធសាសនាមានជម្រៅ៤ យ៉ាងគឺ៖

**១.-ធម្មគម្ភីរៈ** ជ្រៅដោយបាលី

**២.-អត្ថគម្ភីរៈ** ជ្រៅដោយសេចក្តី

**៣.-ទេសនាគម្ភីរៈ** ជ្រៅដោយការសំដែង

**៤.-បដិវេធគម្ភីរៈ** ជ្រៅដោយការត្រាស់ដឹង ។

ពុទ្ធសាសនាមានខ្លឹមសារ៥ យ៉ាងគឺ៖

**១.-សីលសារំ** ខ្លឹមគឺសីល

**២.-សមាធិសារំ** ខ្លឹមគឺសមាធិ

**៣.-បញ្ញាសារំ** ខ្លឹមគឺបញ្ញា

**៤.-វិមុត្តិសារំ** ខ្លឹមគឺវិមុត្តិ ការរួចផុតចាកភព

**៥.-វិមុត្តិញ្ញាណទស្សនសារំ** ខ្លឹមគឺការឃើញថារួចចាកភព ។

មានបង្អែក៣ យ៉ាងគឺ៖

**ព្រះពុទ្ធ១ ព្រះធម៌១ ព្រះសង្ឃ១** ។

មានត្រួយឬពន្លកតែ១ គឺព្រះនិព្វាន ។

ពុទ្ធសាសនាមានម្លប់៣យ៉ាងគឺ៖

**១.-សច្ចំ** សេចក្តីពិតត្រង់

**២.-ខន្តិ** សេចក្តីអត់ធន

**៣.-កតញ្ញូ** អ្នកដឹងគុណ ។

មានចន្ទល់តែមួយ ពោលគឺព្រះវិនយបិដក ។

មានមែក៣យ៉ាងគឺសីល សមាធិ បញ្ញា។ ឬក៏បរិយត្តិធម៌ បដិបត្តិធម៌ បដិវេធ ឬសុត្តន្តបិដក វិនយបិដក អភិធម្មបិដក ។

# គុណភាពនៃសាសនា

សាសនាមានគុណភាព អាចដឹកនាំបុគ្គលអ្នកគោរពរាប់អានឱ្យប្រកបដោយគុណ គឺសេចក្តីល្អឱ្យវៀរចាកនូវអំពើអាក្រក់គ្រប់យ៉ាង ។

ម្យ៉ាងទៀត សាសនាជាគោលសំខាន់សម្រាប់ចង្អុលបង្ហាញនូវផ្លូវដែលគួរប្រព្រឹត្តនិងមិនគួរប្រព្រឹត្តជាបង្អែកយ៉ាងធំមាំ ធ្វើឱ្យមានសេចក្តីក្លាហាន ជាគ្រឿងប្រដាប់ដែលមានសិរីក្រៃលែងជាងគ្រឿងប្រដាប់គ្រប់យ៉ាង ជាគោលធម៌ ឬជាគ្រឿងដៃសម្រាប់ធ្វើឱ្យមនុស្សឱ្យសមភាព ជាមនុស្សពិត ឱ្យសុខ ខុសពីសត្វតិរច្ឆាន ជាគោល ឬជាដួងកែវនៃការសិក្សាពិតៗ ហើយជាគ្រឿងឃុំគ្រងលោក។

# ភ័ស្តុតាងនៃពុទ្ធសាសនា

ពុទ្ធសាសនាមានភ័ស្តុតាង៥ យ៉ាង៖

១. **ព្រះបដិមា** រូបសំណាកព្រះពុទ្ធ ។

២. **ដើមពោធិព្រឹក្ស** ជាឈើដែលព្រះអង្គបានត្រាស់ដឹង ។

៣. **ព្រះស្តូប ឬព្រះចេតិយ** សម្រាប់បញ្ចុះព្រះធម្មក្ខន្ធ និងព្រះអដ្ឋិរបស់ព្រះសម្មាសម្ពុទ្ធ ។

៤. **ព្រះជិនធាតុ** ធាតុរបស់ព្រះជិនស្រី ។

៥. **ព្រះធម្មក្ខន្ធ**៨៤០០០ ដែលតាំងនៅក្នុងភាជន៍គឺបិដកទាំង៣ ។

សាសនា នេះអាចដឹកនាំអ្នកដែលប្រព្រឹត្តប្រតិបត្តិតាមឱ្យឈានឡើងទៅកាន់បណ្ឌិតភាព ឱ្យឡើងពីទុក្ខភាពទៅកាន់សុខភាព ឱ្យឡើងពីអន្ធបុថុជ្ជន ទៅកាន់កល្យាណបុថុជ្ជន ឱ្យឡើងពីកល្យាណបុថុជ្ជន ទៅកាន់អរិយជន វៀរលែងតែអ្នកដែលមិនទាន់បានប្រព្រឹត្តប្រតិបត្តិតាមឱ្យបានហ្មត់ចត់ប៉ុណ្ណោះ ។

អាស្រ័យហេតុ ដូចបានសំដែងមកនេះហើយ ទើបហៅថា **សាសនឆាយា ម្លប់គឺសាសនា** ។

# វុក្ខឆាយាទី៦

ពាក្យថា <<**វុក្ខឆាយា**>> ប្រែថា ម្លប់គឺឈើ ។

ដើមឈើ ក៏រាប់ថាជាម្លប់ប្រសើរបំផុត សំរាប់ជនានុជន អ្នកធ្វើដំណើរពីភូមិមួយទៅភូមិមួយ ពីស្រុកមួយទៅស្រុកមួយ ចូលជ្រកឈប់សំរាក ដែលបានធ្វើដំណើរដោយផ្លូវឆ្ងាយ ដាច់ស្រយាលដើម្បីបន្ទោបង់ការនឿយហត់ ។

ដើមឈើមានប្រយោជន៍ច្រើនជាអនេក មិនអាចពណ៌នា ឱ្យចប់សព្វគ្រប់បាន សព្វថ្ងៃនិយមហៅថាបរិដ្ឋាន ។

**បរិដ្ឋាន**នេះ ពុំមែនសំដៅតែដើមឈើប៉ុណ្ណោះទេ ពាក្យនេះ មានអត្ថន័យដ៏ទូលំទូលាយវែងឆ្ងាយណាស់ ។

ពាក្យថា <<**បរិដ្ឋាន**>> ប្រែថា ទីជុំវិញ ឬកន្លែងជុំវិញ បរិវេណ សំដៅយកអ្វីៗដែលមាននៅក្នុងលោកនេះ ទោះមានវិញ្ញាណក្តី ឥតវិញ្ញាណក្តី ដែលស្ថិតនៅជុំវិញខ្លួនយើងហៅថាបរិដ្ឋាន។

**បរិដ្ឋាន** បានដល់អ្វី? បានដល់សម្បត្តិធម្មជាតិ ។

តើសម្បត្តិធម្មជាតិគឺជាអ្វី?

សម្បត្តិធម្មជាតិ គឺសំដៅយកវត្ថុផ្សេងៗដែលកើតឡើងដោយខ្លួនឯង តាមធម្មជាតិ ហើយជាប្រយោន៍ដល់មនុស្សយើង ដូចជាទឹក ដីភ្នំ ស្ទឹង ដងអូរ ព្រៃឈើ ធាតុរ៉ែ ត្បូង ហើយនិងសត្វព្រៃជាដើម ។

# ទ្រព្យសម្បត្តិធម្មជាតិនិងខ្លួនយើង

ជីវិតប្រចាំថ្ងៃរបស់មនុស្សយើងគ្រប់រូប ត្រូវអាស្រ័យទ្រព្យសម្បត្តិធម្មជាតិជាភាគច្រើន ។ យើង បានជ្រាបស្រាប់ហើយថាជីវិតមនុស្សត្រូវអាស្រ័យនូវបច្ច័យ៤ គឺបានដល់អាហារ គ្រឿងសម្លៀកបំពាក់ ទីស្នាក់អាស្រ័យ ហើយនិងថ្នាំការពាររោគ បច្ច័យទាំង៤នេះ បានមកពីសម្បត្តិធម្មជាតិទាំងអស់ ។

បើគ្មានសម្បត្តិធម្មជាតិហើយ មនុស្សយើងក៏ខ្វះបច្ច័យ៤ ហើយនឹងធ្វើឱ្យមានជីវិតរស់នៅដោយសេចក្តីតាមធម្មតាពុំបាន ។

សម្បត្តិធម្មជាតិ ក្រៅអំពីសម្ពន្ធទាក់ទងជាមួយនឹងខ្លួនយើងហើយ ទ្រព្យសម្បត្តិធម្មជាតិប្រភេទនីមួយៗ នៅតែមានចំណែកសម្ពន្ធគាំទ្រ រវាងគ្នានិងគ្នាជាច្រើន ដូចជាព្រៃឈើជួយឱ្យ

មានភាពជោកជាំ រក្សាមេទឹក ដងស្ទឹង បឹងបួរ និងជាទីកន្លែងស្នាក់អាស្រ័យនៃសត្វព្រៃនិង មនុស្ស បើមិនមានព្រៃឈើទេ នឹងធ្វើឱ្យមានភាពរាំងស្ងួតហួតហែង សត្វព្រៃនឹងបាត់បង់ពូជ អស់ ទឹកក៏ជោរជនលិច ។

ការថែរក្សាសម្បត្តិធម្មជាតិគឺជាអ្វី?

ការថែរក្សាសម្បត្តិធម្មជាតិ គឺជាការចេះប្រើសម្បត្តិធម្មជាតិឱ្យមានប្រយោជន៍ច្រើនជាបំផុត ប្រើបានយូរបំផុត ឱ្យសម្បត្តិធម្មជាតិខូចខាតដោយឥតប្រយោជន៍តិចបំផុត ។ និយាយឱ្យខ្លីគឺ យើងចាំបាច់ ត្រូវតែចេះប្រើសម្បត្តិធម្មជាតិ តាមល្បិចដើម្បីឱ្យមានប្រយោជន៍ខ្ពស់ សន្សំសំចៃបំផុតមិនខ្ជីខ្ជា ហើយរកវិធីកែប្រែវត្ថុដែលមិនល្អ ឬទ្រុឌទ្រោមឱ្យបានល្អឡើងនោះឯង ។

ហេតុម្ដេចបានជាត្រូវថែរក្សាសម្បត្តិធម្មជាតិ?

សម្បត្តិធម្មជាតិ មនុស្សនាំយកមកប្រើ ដើម្បីការផ្គត់ផ្គង់ជីវិតគ្រប់ៗប្រភេទ ទើបធ្វើឱ្យសម្បត្តិធម្មជាតិខូចខាត បាត់បង់ពូជនិងអស់រលីងទៅដោយឆាប់រហ័ស ដូចជា៖

រុក្ខជាតិ សត្វព្រៃ ត្រី សត្វស្លាប ត្រូវចាប់ សម្លាប់ ធ្វើជាអាហារ ។

ព្រៃឈើ កាប់មកប្រើធ្វើជាទីស្នាក់អាស្រ័យ ដុតធ្យូង បាញ់សត្វ ស្ទូចត្រី បរបាញ់សត្វ ។

ទីដីប្រើក្នុងការដាំដុះ ជាកន្លែងរស់នៅ ហើយចិញ្ចឹមសត្វ ប្រើច្រើនទៅៗ ទើបធ្វើឱ្យរលាយ ។

យើងចាំបាច់ត្រូវថែរក្សាការពារសម្បត្តិធម្មជាតិទាំងអស់នេះឱ្យស្ថិតស្ថេរគង់វង្សនៅដដែល ដើម្បីប្រើឱ្យបានយូរតទៅ ។

# ព្រៃឈើ

ពេលប្រជាពលរដ្ឋកើតច្រើនឡើងៗ សេចក្ដីត្រូវការប្រើឈើក៏មានច្រើនឡើងដែរ ។

យើងប្រើឈើសំរាប់សង់ផ្ទះសម្បែង តុទូកៅអី ដែលហៅថាឧបករណ៍ផ្ទះ គ្រឿងប្រើប្រាស់ផ្សេងៗជាច្រើន ។

យើងប្រើឈើឧស ដុតធ្យូង ហើយនិងរបស់ដទៃៗទៀត ។

យើងកាប់ឈើ បំផ្លាញព្រៃ ដើម្បីធ្វើចំការ ធ្វើស្រែ ហើយនិងជាកន្លែងរស់នៅស្នាក់អាស្រ័យ ទើបធ្វើឱ្យព្រៃឈើឱនថយតិចទៅៗ រហូតដល់ជាទីគួរឱ្យតក់ស្លុតថា ព្រៃឈើនឹងអស់ពីប្រទេសខ្មែរ ។

តើព្រៃឈើមានប្រយោជន៍ដល់មនុស្ស ទាំងផ្លូវត្រង់ហើយនិងផ្លូវកាត់ច្រើនប្រការ ដូចជា៖

ប្រយោជន៍ផ្លូវត្រង់ បានដល់៖

សង់ផ្ទះសម្បែង

វត្ថុកសាងដទៃៗ

ធ្វើគ្រឿងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ

ធ្វើក្រដាស

ក្តារ កុង ផ្ទាកកេ

តតាកផ្ទះ

ធ្វើទ្រុងឡានដឹកទំនិញ ហើយដទៃទៀតជាច្រើន ។

ប្រយោជន៍ផ្លូវកាត់ បានដល់÷

ជួយការពារ និងរក្សាដីមិនឱ្យរលំរលាយ

ការពារទឹកលិច

ធ្វើឱ្យធាតុអាកាសជោកជាំ ស្រស់បំព្រង ម្ទប់ត្រជាក់

ជាកន្លែងស្នាក់អាស្រ័យរបស់សត្វស្លាប និងសត្វព្រៃ

ជាកន្លែងស្នាក់អាស្រ័យ បណ្តែតអារម្មណ៍

ធ្វើទេសភាព ប្រទេសស្អាតស្អំ ។ល។

តើយើងនឹងថែរក្សាព្រៃឈើបានដូចម្តេច?

ការពារ ការរុករានបំផ្លិចបំផ្លាញព្រៃ ធ្វើការកំប៉ិកកំប៉ុកមិននឹងន៍

ការពារការលួចលាក់កាប់ឈើ ហើយនិងការរំលំឈើ ដើម្បីលក់ដូរ ដែលជាភ័យអាសន្ន ដ៏កាចសាហាវនៅក្នុងខណៈនេះ

ការពារសេចក្តីខូចខាត ពីភ្លើងឆេះព្រមទាំងកើតឡើងឯងដោយធម្មជាតិ ការចោលកន្ទុយបារីនិងដុតសំរាមនិងរុក្ខជាតិដែលងាប់

ការចេះប្រើឈើឱ្យសំចៃ និងឱ្យមានប្រយោជន៍ជាដើម។

យើងត្រូវជួយគ្នាឃ្លាំមើល ការពារការកាប់ឈើ បំផ្លាញព្រៃ មិនថាដោយពិធីណា។ឡើយ បើសិនជាជួបប្រទះឃើញត្រូវប្តឹងចៅនាទី ដំណើរការណ៍តាមច្បាប់ភ្លាម ។

# អំពីសត្វព្រៃ

នាក្នុងអតីតកាល ប្រទេសខ្មែរមានសត្វព្រៃច្រើនបំផុត ជាទូទៅ តែបច្ចុប្បន្ននេះ សត្វព្រៃរាល់ថ្ងៃ កាន់តែពិបាករកទៅហើយ គួរឱ្យត្រិះរិះកង្វល់មនុស្សជំនាន់ក្រោយ។ មិនមានឱកាសនឹងបានឃើញ បានស្គាល់សត្វព្រៃទាំងអស់នោះទេ ដូចជារមាស រមាំង ទន្សាយ ទន្សោង គោព្រៃ ក្របីព្រៃជាដើម ។ល។

សត្វព្រៃមានប្រយោជន៍ដល់មនុស្សយើងយ៉ាងណាខ្លះ?

សត្វព្រៃមានប្រយោជន៍ច្រើនផ្នែកជាដើមថា÷

ផ្នែកសេដ្ឋកិច្ច សត្វព្រៃច្រើនប្រភេទ យើងនាំមកធ្វើជា អាហារ ជី ថ្នាំការពារ រោគ សាប៊ូ គ្រឿងសម្លៀកបំពាក់ គ្រឿងប្រដាប់ប្រដាលំអ ផលិតភ័ណ្ឌ ហើយនិងឧស្សាហកម្មផ្សេង។

ផ្នែកការទស្សនកិច្ច និងសម្រាកកាយបណ្តែតអារម្មណ៍

ផ្នែកភាពស្អាត ស្រស់បំព្រងតាមធម្មជាតិ សត្វព្រៃច្រើនប្រភេទ មានភាពស្អាតស្រស់ សម្លេងសូរសៀងពីរោះ

ធ្វើឱ្យព្រៃឈើរីកសាយបែកពូជ ។

យើងនឹងជួយការពារសត្វព្រៃបានយ៉ាងណាខ្លះ?

មិនរុករានបំពានព្រៃឈើ ដែលជាប្រភព ទីស្នាក់អាស្រ័យនៃសត្វព្រៃ ទាំងព្រៃឈើ ស្ទឹង ភ្នំ ដង អូរមិនឱ្យឆ្លុះបរបាញ់សម្លាប់ដោយវិធីផ្សេៗ មិនថាជាការបាញ់ ដាក់អន្ទាក់ ចាប់បញ្ឆោត ហើយ និងដេញ

ប្រើជាតិគីមី និងថ្នាំសម្លាប់សត្វល្អិតយ៉ាងប្រយ័ត្នប្រយែង បំផុតដើម្បីមិនឱ្យមានគ្រោះថ្នាក់ សត្វព្រៃមិនឱ្យមានភ្លើងឆាបឆេះកើតឡើង ព្រៃឈើជាចំណុចរួមសំខាន់ក្នុងការផ្គត់ផ្គង់ ជីវិត របស់សត្វព្រៃគឺជាកន្លែងស្នាក់អាស្រ័យ ប្រភពទឹក ប្រភពអាហារ និងប្រភពលាក់បំពួនបិទបាំង គ្រោះអាសន្ន យើងត្រូវជួយគ្នា រួមគ្នា កុំរុករានបំពានបំផ្លាញព្រៃ កុំត្រុយកាប់ឆ្ការព្រៃនិងដុតព្រៃ ព្រោះនឹងនាំឱ្យសត្វព្រៃមានចំនួនអន់ថយតិចចុះ ហើយនឹងនាំឱ្យសូន្យបាត់បង់ពូជក្នុងកាលជាទី បំផុត ។ ដូច្នេះប្រភពសត្វព្រៃទាំងនោះ មានប្រយោជន៍ដល់សេដ្ឋកិច្ច ដែលមិនអាចកាត់ថ្លៃបាន ឡើយ ។ សូមបងប្អូនឈ្លួញគ្រប់សាសន៍ ឈប់ទិញសត្វព្រៃ ហើយយើងប្តេជ្ញាការពារវាឱ្យមាន សុវត្ថិភាពនិងការរីកចំរើន ។ ឯព្រៃឈើក៏ដូច្នោះដែរ ដោយយើងយល់ថា៖

ដើម្បីជួយក្នុងការ ដាំដុះដំណាំផ្សេងៗ

ដើម្បីអាចជួយបង្កើតបង្កើន គុណភាពដី និងការពារហូរច្រោះជីវជាតិ

ដើម្បីជាប្រភពដ៏ប្រសើរនិងប្រភពផ្តល់នូវសម្ភារៈសំណង់ផ្សេងៗ

ព្រៃឈើជាអាយុជីវិតនៃកសិកម្ម

ព្រៃឈើជាអាយុជីវិតសត្វលោក

ដាំដើមឈើ គឺស្រោចស្រង់បរិយាកាស

ព្រៃឈើជាប្រភពនៃទឹក និងស្រោចស្រប់បរិយាកាស ។

បញ្ជាក់សេចក្តីថា៖

ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គកាលប្រសូត ក៏ប្រសូតក្នុងព្រៃ(សួនឧទ្យានលុម្ពិនី) កាលត្រាស់ដឹង ក៏ត្រាស់ដឹងក្រោមដើមពោធិព្រឹក្ស កាលបរិនិព្វាន ក៏បរិនិព្វានក្រោមដើម សាលព្រឹក្សដែលយើងនិយមហៅថា(ដើមរាំងទាំងគូ) ក្នុងឧទ្យានរបស់មល្លក្សត្រ ។

កាលព្រះសម្ពុទ្ធទ្រង់ធរមាននៅឡើយគឺថ្ងៃពេញបូណ៌មី ខែមាឃ ព្រះអង្គធ្វើចតុរង្គសន្និបាត ប្រជុំសាវ័ក សំដែងនូវឱវាទបាដិមោក្ខ ដល់សាវ័ក ជាព្រះអរហន្ត ចំនួន១២៥០អង្គ ក្នុងវត្ត វេឡុវ័ន ក្រុងរាជគ្រឹះ ។

ពុទ្ធោវាទទាំងអស់មានចំនួន១១បទ តែចំពោះ ឱវាទទី១០ ត្រង់បទបាលីថា៖ បន្តញ្ច សយនាសនំ ប្រែថា ទីដេកទីអង្គុយ ដ៏ស្ងាត់។ ព្រះពុទ្ធអង្គទ្រង់សរសើរថា ការរស់នៅក្នុងព្រៃភ្នំថា

ជាទីដ៏ស្ងាត់ សំរាប់ព្រះយោគាវចរ អ្នកស្វែងរកធម៌ព្រមទាំងត្រាស់សំដែងប្រាប់ អានិសង្សនៃការរស់នៅក្នុងព្រៃ និងគុណនៃរុក្ខមូល ការរស់នៅទៀបគល់ឈើ សមនឹងព្រះពុទ្ធដីកាថា រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា ប្រែថា អ្នកបួសត្រូវអាស្រ័យនៅទៀបគល់ឈើជាសេនាសនៈ ។

ម្យ៉ាងទៀត ដូចមានព្រះពុទ្ធដីកា ក្នុងអនុសាសនវិធី(ដែលយើងហៅថាផ្តាំនាគ) ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់បង្គាប់ ឱ្យភិក្ខុប្រៀនប្រដៅភិក្ខុដែលបួសថ្មី ក្នុងវេលាចប់ញត្តិចតុត្ថកម្មវាចាថ្មីៗថា៖រុក្ខមូលសេនាសនំ និស្សាយ បព្វជ្ជា តត្ថតេ យាវជីវំ ឧស្សាហោ ករណីយោ ប្រែថា អ្នកបួសត្រូវអាស្រ័យនៅទៀប គល់ឈើជាសេនាសនៈ(ទីដេកទីអង្គុយ សេចក្តីព្យាយាម ក្នុងការអាស្រ័យនៅដោយរុក្ខមូលសេនាសនៈ នោះ អ្នកគប្បីធ្វើជាដរាបដល់អស់ជីវិត) ។ រុក្ខមូលសេនាសនៈរមែងជាទីអភិរម្យ របស់ព្រះយោគី អ្នកប្រាថ្នាសេចក្តីស្ងប់រម្ងាប់ជាធម្មតា ទីដែលព្រះបរមគ្រូទ្រង់ប្រសូត ទ្រង់ត្រាស់ដឹង ទ្រង់បរិនិព្វាន សុទ្ធតែក្នុងព្រៃជាសេនាសនៈ ដ៏ស្ងាត់ទាំងអស់ ។

បញ្ជាក់សេចក្តីឱ្យកាន់តែច្បាស់លាស់ថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ព្រះអង្គយល់យ៉ាងប្រត្យ័ក្ស ចំពោះពាក្យថា បរិដ្ឋាន ព្រមទាំងត្រាស់សរសើរ លើកតម្កើតម្កើង ចំពោះព្រៃឈើនេះ ហើយនិងអ្នកដែលរស់នៅក្នុងព្រៃឈើដូចជាព្រះយោគាវចរ អ្នកស្វះស្វែងរកមោក្ខធម៌ ដើម្បីរើខ្លួនឱ្យរួចផុតចាកសេចក្តីទុក្ខក្នុងវដ្តសង្សារនេះ ក៏សុទ្ធតែត្រូវការព្រៃឈើ ដែលជាទីស្ងាត់ចាកអារម្មណ៍ទាំងអស់ ។

ធម៌ទេសសនាដែលបានសំដែងមក អំពីឆាយាធម៌៦ យ៉ាងក៏សន្មតថាចប់តែត្រឹមប៉ុណ្ណេះ

**សាសនស្ស ច លោកស្ស វុឌ្ឍី ភវតុ សព្វទា**

**សាសនម្បិ ច លោកញ្ច ទេវា រក្ខន្តុ សព្វទា ។**

( ដោយអានុភាពនៃធម្មទេសនានេះ) សូមឱ្យព្រះពុទ្ធសាសនានិងសត្វលោក មានសេចក្តីចំរើនគ្រប់ៗកាល! សូមទេវតាទាំងឡាយរក្សានូវព្រះពុទ្ធសាសនាផង នូវសត្វលោកផង ( ឱ្យបានសេចក្តីសុខ-ចំរើន) គ្រប់ៗកាល!

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**

**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ពុទ្ធិកា ។**

( ដោយអានុភាពនៃធម្មទេសនា ដោយអានុភាពនៃកុសលចិត្តរបស់ពុទ្ធបរិស័ទ ដែលបានគោរពបូជាស្តាប់ធម្មទេសនានេះ) សូមពុទ្ធបរិស័ទទាំងអស់ ដែលដល់នូវទុក្ខ សូមឱ្យបាត់នូវទុក្ខ! ដែលដល់នូវភ័យ សូមឱ្យបាត់នូវភ័យ! ដែលដល់នូវសោកក្រៀមក្រំ សូមឱ្យបាត់នូវសោកក្រៀមក្រំទៅ!